# របាយការណ៍

## ស្តីពី

### លទ្ធផល និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

ថ្លែងដោយឯកឧត្តម **គេង សាវឌ្ឍ** ក្នុងឱកាសប្រជុំការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៥

និង ផ្សព្វផ្សាយផែនការជាតិ៥ឆ្នាំ(២០០៥-២០១០)

( ថ្ងៃពុធទី០៧ ខែកញ្ញា ឆ្នាំ២០០៥ )

សូមគោរព

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ

-ឯកឧត្តម លោកជំទាវ លោក លោកស្រី

ថ្ងៃនេះ ខ្ញុំមានកិត្តិយសក្រៃលែងដែលបានចូលរួមនៅក្នុងកិច្ចប្រជុំការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៥និងផ្សព្វផ្សាយផែនការជាតិ៥ឆ្នាំរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។ ជាបឋមខ្ញុំសូមអនុញ្ញាតជំរាបជូនឯកឧត្តមប្រធាននិងអង្គប្រជុំទាំងមូលនូវស្ថានភាពគ្រឿងញៀនបច្ចុប្បន្ន និងទិសដៅការងាររបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដូចតទៅ :

## I / <u>សភាពការណ៍គ្រឿងញៀន</u> :

បច្ចុប្បន្នគ្រឿងញៀនបានក្លាយជាបញ្ហាដ៏គ្រោះថ្នាក់សំរាប់ប្រទេសជាច្រើននៅលើពិភពលោក ។ ជាមួយគ្នានោះកម្ពុជាយើងក៏ក្លាយជាប្រទេសមួយដែលទទួលរងនូវវិនិន្នាការនៃការចរាចរឆ្លងកាត់ និងការជួញដូរចែកចាយនូវគ្រឿងញៀនជាច្រើនប្រភេទ ។ វាជាបញ្ហាព្រួយបារម្ភសំរាប់សង្គមកម្ពុជា ដោយសារមជ្ឈដ្ឋានអន្តរជាតិជាទូទៅបានវាយតម្លៃថាប្រទេសយើងកំពុងក្លាយជាច្រកចរាចរថ្មីសំរាប់ទីផ្សារគ្រឿងញៀនទាំងនៅក្នុងតំបន់និងអន្តរជាតិ ។

១-<u>ការដាំដុះ និង ការចរាចរ គ្រឿងញៀនកញ្ឆា</u> : រហូតមកដល់បច្ចុប្បន្ននេះ នៅមានការដាំដុះដំណាំកញ្ឆាតិចតួចប៉ុណ្ណោះ ។ ខេត្តដែលនៅមានការដាំដុះភាគច្រើនជាខេត្តស្ថិតនៅតាមបណ្តោយព្រំដែនភាគពាយ័ព្យ និងខេត្តស្ថិតនៅតាមដងទន្លេមេគង្គ ។ ទោះបីជានៅមានការដាំដុះក៏ពិតមែន តែគ្មានសញ្ញាជាថ្មីបង្ហាញថាកញ្ឆាត្រូវបានគេធ្វើការដឹកជញ្ជូននាំចេញដោយទ្រង់ទ្រាយធំតាមច្រកកំពង់ផែសមុទ្រដូចនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ៩០ទៀតទេ ។

២-<u>ការចរាចរគ្រឿងញៀនសំយោគ ATS</u> : ៩ខែនេះ ប្រភេទគ្រឿងញៀនសំយោគ ATS នៅតែបន្តធ្វើចរាចរឆ្លងកាត់តំបន់ព្រំដែនតាមច្រកសំខាន់បីគឺ ច្រកស្រុកឆែប(ខេត្តព្រះវិហារ) និងច្រកស្រុកថាឡាបរិវ៉ាត់, ស្រុកសៀមប៉ាង(ខេត្តស្ទឹងត្រែង) ។

ការនាំឆ្លងកាត់ច្រកព្រំដែននៃស្រុកឆែបរបស់ខេត្តព្រះវិហារយើងបានកត់សំគាល់ឃើញមានសកម្មភាពពីរគឺ មួយចំនួនត្រូវបានពួកឈ្មួញនាំបន្តមកកាន់ស្រុកថាឡាបរិវ៉ាត់ខេត្តស្ទឹងត្រែង។ មួយចំនួនទៀតធ្វើចរាចរឆ្លងកាត់តាមខេត្តកំពង់ធំ

ក្នុងទិសដៅចែកចាយតាមបណ្តាខេត្តភាគពាយ័ព្យរួមមាន ខេត្តសៀមរាប បាត់ដំបង និងបន្ទាយមានជ័យ( សំខាន់តំបន់ប៉ោយ-ប៉ែត) ។

ចំពោះការនាំឆ្លងកាត់ស្រុកថាឡាបរិវ៉ាត់ គឺមានទិសដៅចរាចរចែកចាយឱ្យបណ្តាខេត្តនានាតាមដងទន្លេមេគង្គរួមមាន ខេត្តក្រចេះ កំពង់ចាម កណ្តាល ភ្នំពេញ ។ ថ្មីៗនេះ មាន១ករណីបានធ្វើចរាចរក្នុងទ្រង់ទ្រាយធំទៅដល់ខេត្តកំពតដែលសមត្ថកិច្ចធ្វើការរឹបអូសបាន ១០០.០០០ គ្រាប់ ។

ដោយឡែក ការនាំឆ្លងកាត់ច្រកព្រំដែននៃស្រុកសៀមប៉ាង( ខេត្តស្ទឹងត្រែង) គឺមានទិសដៅនាំបន្តទៅកាន់ស្រុកវើនខាំរបស់ខេត្តរតនគីរី ។ តាមការធ្វើគណនាការហូរចូលកន្លងមកតាមច្រកទាំងនោះគឺមានប្រហែលជាង៨០%នៃចំនួន ATSសរុបដែលរឹបអូសបាន ២៣៣.០១៥ គ្រាប់ ។ ចំណែក អ៊ិចស្តាស៊ី និង កូកាអ៊ីន ភាគច្រើនត្រូវបានក្រុមឧក្រិដ្ឋជនអន្តរ-ជាតិនាំពីទ្វីបអឺរ៉ុបចូល មកកម្ពុជាតាមផ្លូវអាកាស ។

ក្រៅពីបណ្តាខេត្តក្រុងដែលមានការពាក់ព័ន្ធសំខាន់នឹងផ្លូវចរាចរខាងលើ យើងពិនិត្យឃើញ ក្រុងប៉ៃលិន ក្រុងព្រះសី-ហនុ ខេត្តកោះកុង ពោធិសាត់ កំពត តាកែវ កំពង់ស្ពឺ ក៏បានរួមចំណែកយ៉ាងសកម្មក្នុងការបោសសំអាតបទល្មើសគ្រឿងញៀនផងដែរ ។

៣-<u>ហេរ៉ូអ៊ីន</u> : កម្ពុជាក៏ជាប្រទេសគ្មានការផលិតហេរ៉ូអ៊ីនដែរ ។ តំបន់ត្រីកោណមាស គឺជាប្រភពដ៏សំខាន់ដែលឧក្រិដ្ឋជនអន្តរជាតិនាំហេរ៉ូអ៊ីនចូលមកកម្ពុជាតាមច្រកភាគឦសានសំខាន់គឺច្រកនៃខេត្តស្ទឹងត្រែង ។

ការលាក់គ្រឿងញៀននៅនឹងខ្លួនឬដាក់បន្លំក្នុងបញ្ញើប្រៃសណីយ៍, ការលាក់បង្កប់គ្រឿងញៀនក្នុងទំនិញស្របច្បាប់ដើម្បីនាំឆ្លងកាត់តំបន់ព្រំដែនដោយចាត់តាំងប្រជាជនសាមញ្ញ ឬ ក្រុមអនីតិជនឱ្យនាំចូលគឺជាល្បិចកលទូទៅដែលកំពុងប្រើប្រាស់ដោយពួកឧក្រិដ្ឋជន។

៤-<u>កេតាមីន</u> :

ប៉ុន្មានឆ្នាំកន្លងមកនេះ នៅកម្ពុជាពិនិត្យឃើញការរត់ពន្ធកេតាមីនបានចាប់ផ្តើមកើតមានឡើង ។ ក្នុងឆ្នាំ២០០១ក្រុមឧក្រិដ្ឋជនបរទេសធ្លាប់បាននាំកេតាមីនប្រភេទគ្រាប់ចំនួន៩.៨៤៧គ្រាប់និងប្រភេទម្សៅចំនួន៥គ.ក្រ ឆ្លងកាត់កម្ពុជាតាមផ្លូវអាកាសទៅកាន់ប្រទេសទី៣ ដែលពេលនោះមន្ត្រីគយនិងមន្ត្រីនគរបាលប្រចាំការនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញធ្វើការបង្ក្រាបទាន់ពេលវេលា ។ ឆ្នាំក្រោយៗមកទៀត យើងបានរកឃើញជាបន្តបន្ទាប់នូវកេតាមីនប្រភេទទឹកដែលឧក្រិដ្ឋជនបានធ្វើការដឹកជញ្ជូនតាមផ្លូវគោកឆ្ពោះទៅកាន់តំបន់ប៉ោយប៉ែត ។ ទើបតែនៅក្នុងខែធ្នូឆ្នាំ២០០៣ កេតាមីនត្រូវបានក្រសួងសុខាភិបាលចេញប្រកាសដាក់បញ្ចូលបន្ថែមទៅក្នុងតារាងឧបសម្ព័ន្ធ III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥-<u>សារធាតុគីមីផ្សំ</u> :

ក្នុងចំណោមសារធាតុគីមីជាច្រើនមុខដែលនាំចូលមកកម្ពុជា យើងបានកត់សំគាល់ឃើញថាអាស៊ីដស៊ុលផួរិចត្រូវបាននាំចូលច្រើនជាងគេក្នុងមួយឆ្នាំៗ ។ ក្រៅពីការប្រើប្រាស់អាស៊ីដស៊ុលផួរិចក្នុងផលិតកម្មស្របច្បាប់ យើងបានរកឃើញការបង្វែរសារធាតុនោះដោយខុសច្បាប់ទៅផ្សំចំរាញ់យកប្រេងម្រះព្រៅ ដែលនៅក្នុងប្រេងនោះមានផ្ទុកសារធាតុ **សាហ្វ្រូល** ដែលជាសារធាតុគីមីផ្សំសំខាន់ក្នុងការផលិតគ្រឿងញៀន ។

ក្រៅពីនោះ នៅមានការប្រើប្រាស់អាស៊ីដស៊ុលផួរិចដោយលួចលាក់ក្នុងការផ្សំចំរាញ់យកម្សៅ **វីល្លិល្បៀត** ដែលច្បាប់បានហាមឃាត់ ។ យើងកំពុងយកចិត្តទុកដាក់សំរបសំរួលនិងជំរុញយន្តការត្រួតពិនិត្យចំពោះសារធាតុគីមីដើម្បីបង្ការទប់ស្កាត់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែននិងការបង្វែរទៅផលិតគ្រឿងញៀនខុសច្បាប់ ។

៦-<u>ការប្រើបំពានគ្រឿងញៀន</u> :

ATS គឺជាប្រភេទគ្រឿងញៀនដ៏សំខាន់ ដែលកំពុងមានការប្រើប្រាស់បំពាននៅក្នុងប្រទេស ជាពិសេសក្នុងចំណោមយុវវ័យ / ពលករ / អ្នកបើករថយន្តតាក់ស៊ី / កម្មកររោងចក្រ / កម្មករសំណង់និងលីសែង សុទ្ធតែជាក្រុមដែលងាយទទួលរងគ្រោះថ្នាក់បំផុត ។ ពិតមែនមិនទាន់មានតួលេខគ្រប់គ្រាន់ ប៉ុន្តែមានសន្ទស្សន៍បង្ហាញថាអ្នកញៀនមានចំនួនកើនឡើងជារៀងរាល់ឆ្នាំ ។ ជាមួយនោះ យើងក៏បានកត់សំគាល់ឃើញការប្រើបំពានគ្រឿងញៀនបច្ចុប្បន្នបានរីករាលដាលដល់ក្រុមយុវជនក្រីក្រជាច្រើន ដែលនាំឱ្យមានយុវជនមួយចំនួនបានធ្លាក់ទៅក្នុងការអូសទាញរបស់ក្រុមទុច្ចរិត ។ បញ្ហាដែលគួរឱ្យព្រួយបារម្ភនោះគឺការចម្លងមេរោគអេដស៍តាមរយៈការប្រើប្រាស់ម្ជុលស៊ីរ៉ាំងរួមគ្នា ក្នុងការចាក់បញ្ចូលគ្រឿងញៀនតាមសរសៃឈាម និងការរួមភេទមិនធានាសុវត្ថិភាព ។

II / **<u>លទ្ធផលក្នុងការប្រឆាំងទប់ស្កាត់បញ្ហាគ្រឿងញៀន</u>** :

**១_ការងារអនុវត្តច្បាប់ :**

**ក -កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស :**

គិតត្រឹមខែសីហានេះ សមត្ថកិច្ចអនុវត្តច្បាប់បង្ក្រាបបទល្មើសបាន **២៦៥** ករណី, ចាប់ខ្លួនជនល្មើសបាន **៥១៤** នាក់ ក្នុងនោះគឺ :

- **-ករណី** ATS : បង្ក្រាបបាន **២៥១** ករណី, រឹបអូស ATS ,ឃាត់ខ្លួនជនល្មើសចំនួន**៤៨៨** នាក់ និងរឹបអូសATS ចំនួន **២៣៣.០១៥** គ្រាប់ ។
- **-ករណីហេរ៉ូអ៊ីន និង អូផ្យូមអាល់កាឡូអ៊ីដ :** បង្ក្រាបបាន **៨** ករណី, ឃាត់ខ្លួនជនល្មើសចំនួន **៩** នាក់ និងរឹបអូសហេរ៉ូអ៊ីននិងអូផ្យូមអាល់កាឡូអ៊ីដបានចំនួន **១១,០៦** គ.ក្រ ។
- **-ករណីកូកាអ៊ីន :** បង្ក្រាបបាន **១** ករណី, ឃាត់ខ្លួនជនល្មើសចំនួន**១** នាក់ ជាជនជាតិបរទេស និងរឹបអូសបានកូកាអ៊ីន ចំនួន **១** គ.ក្រ ។
- **-ករណីកញ្ឆា :** បង្ក្រាបបាន **២** ករណី, ឃាត់ខ្លួនជនល្មើស **១៣** នាក់ និងរឹបអូសកញ្ឆាបាន**១០២,៥០** គ.ក្រ ។
- **-ករណីចាប់តាមដីកាតុលាការ :** **៣** ករណី, ឃាត់ខ្លួនជនល្មើស **៣** នាក់ និងរឹបអូសកាំភ្លើង AK 47 មួយដើម ។

**ខ -លទ្ធផលបំផ្លាញដំណាំកញ្ឆា :**

អាជ្ញាធរខេត្តបន្ទាយមានជ័យ និង ខេត្តកំពង់ចាម បានធ្វើការបំផ្លាញដំណាំកញ្ឆាចំនួន ១.០៩០ ដើម ដែលគិតជាផ្ទៃដីស្មើនឹង ២១៨ ម៉ែត្រក្រឡា ( មានន័យថាការដាំដុះដំណាំកញ្ឆាបានថយចុះដល់កំរិតអតិបរិមា) ។

**ឥ-ការងារពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ :**

យើងបានយកចិត្តទុកដាក់ក្នុងការបើកវគ្គបំពាក់បំប៉នដល់មន្ត្រីអនុវត្តច្បាប់នានារួមមាន កងកម្លាំងនគរបាល កងរាជអាវុធហត្ថ មន្ត្រីគយ-រដ្ឋាករ មន្ត្រីកំពង់ផែស្វយ័តក្រុងព្រះសីហនុ មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន(BLO)..... អំពីជំនាញអនុវត្តច្បាប់ដោយប្រើប្រាស់កុំព្យូទ័រជាមូលដ្ឋាន(CBT), ជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំតាមរយៈឯកសារ DVD.... សរុបបានចំនួន **៧៦៣** នាក់ ។

**ឃ-លទ្ធផលនៃការវិភាគលើសំណាកវត្ថុតាង :**

យើងបានធ្វើវិភាគលើសំណាកវត្ថុតាង របស់បណ្តាអង្គភាពអនុវត្តច្បាប់និងស្ថាប័នតុលាការដែលបញ្ជូនមក ជាលទ្ធផលបានរកឃើញ គ្រឿងញៀនសំយោគATSមានប្រមាណ៧០%, ហេរ៉ូអ៊ីនប្រមាណ១៦% ហើយក្រៅពីនោះជាប្រភេទគ្រឿងញៀនផ្សេងៗទៀតដូចជា : កូកាអ៊ីន, កញ្ឆា....... ជាដើម។ល ។

**ង-សកម្មភាពត្រួតពិនិត្យសារធាតុគីមីផ្សំ :**

តាមរយៈការិយាល័យBLOប៉ោយប៉ែត និង ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ យើងក្តាប់បានពីការនាំចូលនូវសារធាតុគីមីផ្សំជាច្រើនប្រភេទ ដែលក្នុងនោះអាស៊ីដស៊ុលផួរិចត្រូវបានគេនាំចូលច្រើនជាងគេ ។ អគ្គលេខាធិការដ្ឋានបានយកចិត្តទុកដាក់សំរបសំរួលនិងធ្វើការណែនាំដល់បណ្តាក្រុមហ៊ុនទាំងនោះ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការធ្វើចរាចរចែកចាយនៅលើទីផ្សារ ដោយសារសារធាតុនេះអាចបង្វែរទៅផលិតជាគ្រឿងញៀនខុសច្បាប់បាន ។

**ច-ការងារស្រង់ស្ថិតិអ្នកប្រើគ្រឿងញៀន :**

តាមស្ថិតិដែលទើបដំណើរការស្រង់នៅក្នុង១៥ខេត្តក្រុងគឺ ក្រុងភ្នំពេញ, ក្រុងប៉ៃលិន, ក្រុងព្រះសីហនុ, ខេត្តបាត់ដំបង បន្ទាយមានជ័យ, កោះកុង, សៀមរាប, ពោធិសាត់, កណ្តាល, កំពង់ចាម, កំពង់ស្ពឺ, តាកែវ, ព្រៃវែង, ស្ទឹងត្រែង និង ក្រចេះ អ្នកប្រើគ្រឿងញៀនសរុបមានចំនួន ៦.៨៧៦ នាក់ ។ កត់សំគាល់ អ្នកប្រើគ្រឿងញៀននៅក្រុងភ្នំពេញមានតួលេខខ្ពស់ជាងគេ និងចំណាត់ថ្នាក់បន្តបន្ទាប់គឺខេត្តបាត់ដំបង, បន្ទាយមានជ័យ, ក្រុងព្រះសីហនុ, កំពង់ចាម........ ។

អ្នកប្រើប្រាស់ទាំងនោះស្ថិតនៅក្នុងចំណោមកម្មករ, សិស្ស, ក្មេងអនាថា និង ជនដែលគ្មានមុខរបរពិតប្រាកដ ។ ប្រភេទគ្រឿងញៀនដែលពួកគេប្រើរួមមាន គ្រឿងញៀនសំយោគ ATS ហេរ៉ូអ៊ីន និង កាវ ។ ទោះបីតួលេខនេះមិនទាន់គ្រប់គ្រាន់ ប៉ុន្តែបានបង្ហាញពីការកើនឡើងហើយយើងជឿថាអ្នកប្រើគ្រឿងញៀនពិតប្រាកដអាចនឹងមានចំនួនច្រើនជាងនេះ។

**២. ការកាត់បន្ថយតំរូវការ និង ការបង្ការការប្រើបំពានគ្រឿងញៀន :**

កិច្ចការនេះ យើងបាន :

-បង្កើនកម្មវិធីលើកកំពស់ការយល់ដឹងជាសាធារណៈ អំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា ក្នុងការផលិតបន្ថែមនូវឯកសារសំរាប់ការអប់រំនិងបានធ្វើការផ្សព្វផ្សាយ តាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន.... ។ ថ្មីៗនេះយើងបានសហការជាមួយអង្គការសុខភាពពិភពលោក / អង្គការកម្មវិធីរួមសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍ / ការិយាល័យUNODC នៅទីក្រុងភ្នំពេញ / អង្គការក្រៅរដ្ឋាភិបាលនានា និង

អង្គការកម្មវិធីបង្ការការពារជំងឺឆ្លង(USCDC)របស់សហរដ្ឋអាមេរិក ធ្វើការផ្សព្វផ្សាយនូវរបាយការណ៍២ ស្តីពីការប្រើប្រាស់គ្រឿងញៀននិងភាពគ្រោះថ្នាក់នៃការចម្លងមេរោគអេដស៏នៅកម្ពុជា ។

-យើងបានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលសង្ឃចំនួន១៨០អង្គ មកពីវត្ត២១ក្នុងខេត្តក្រុងចំនួន៤រួមមាន ភ្នំពេញ បាត់ដំបង បន្ទាយមានជ័យនិងសៀមរាប ក្នុងទិសដៅចលនាវត្តអារាមនិងព្រះសង្ឃចូលរួមសកម្មភាពអប់រំបង្ការគ្រឿងញៀនតាមពុទ្ធឱវាទ និង បណ្តុះបណ្តាលមន្ត្រីជំនាញផ្នែកឃោសនា រួមទាំងចូលរួមក្នុងវេទិកាសាធារណៈ / សិក្ខាសាលានានា...។

-យើងកំពុងរៀបចំបង្កើតក្រុមការងារបច្ចេកទេសទទួលបន្ទុកកិច្ចការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងកំពុងកែសំរួលលើសេចក្តីព្រាងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការអនុវត្តនីតិវិធានការអប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្ថែមពីលើនោះ គំរោងការបង្កើតមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ក៏បានឯកភាពគ្នាដោយក្រុមការងារអន្តរក្រសួងសមាជិក អ.ជ.ប.គ.ញ ជាមួយអាជ្ញាធរដែនដីថានឹងបង្កើតមជ្ឈមណ្ឌលនេះ១កន្លែងនៅក្រុងភ្នំពេញ ។

-អគ្គលេខាធិការដ្ឋានបានក្រសួងអប់រំយុវជននិងកីឡា បានបញ្ចូលបន្ថែមបញ្ហាគ្រឿងញៀនទៅក្នុងកម្មវិធីអប់រំរហូតដល់ថ្នាក់ឧត្តមសិក្សា ។

-យើងបានផ្តល់ជូននូវ អាវយឺតចំនួន៦៥០, មួកចំនួន៦៥០, រូបភាពសំរាប់ផ្សព្វផ្សាយសរុប៦.៤០០សន្លឹក និងសំភារៈមួយចំនួនទៀតដល់ខេត្តក្រុងសំខាន់ៗចំនួន១៤ ដើម្បីចូលរួមប្រារព្វទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ មិថុនា ២០០៥ ក្រោមប្រធានបទ"ឱ្យតំលៃលើខ្លួនអ្នក... ធ្វើការសំរេចចិត្តឱ្យបានត្រឹមត្រូវ" ដែលមានព្រះសង្ឃនិងមហាជនចូលរួមប្រមាណជាង១០.០០០នាក់ ។ ដោយឡែក នៅក្រុងភ្នំពេញនិងនៅខេត្តសៀមរាប ទិវានេះត្រូវបានចូលរួមដឹកនាំផ្ទាល់ដោយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ។

**៣-ការងារនីតិកម្ម :** យើងបានខិតខំសំរេចនូវកិច្ចការសំខាន់ៗជាច្រើនដែលពាក់ព័ន្ធទៅនឹងការងារនេះគឺ :

-ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវបានធ្វើវិសោធនកម្មក្នុងបំណងបន្ថែមទម្ងន់ទោសចំពោះជនល្មើស ។

-អនុសញ្ញាអន្តរជាតិឆ្នាំ១៩៦១-១៩៧១ និង ១៩៨៨ ស្តីពីគ្រឿងញៀនត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋសភា ។

-ផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កំពុងអនុវត្តចាប់តាំងពីឆ្នាំ២០០៥ នេះតទៅ ។

-ផែនការជាតិប្រចាំឆ្នាំ២០០៦ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កំពុងរៀបចំស្នើសុំការយល់ព្រមពី អ.ជ.ប.គ.ញ ។

-ព្រះរាជក្រិត្យស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កំពុងតែធ្វើការពិនិត្យនឹងកែសំរួល ។

-សេចក្តីព្រាងគោលនយោបាយស្តីពីការព្យាបាល និង ស្តារនីតិសម្បទា កំពុងតែធ្វើការកែសំរួល ។

-ប្រកាសស្តីពី "ការប្រគល់ដោយមានការឃ្លាំមើលនិងការពន្យារពេលដើម្បីចាប់" កំពុងតែពិនិត្យ និង កែសំរួល ។

**៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ :**

យើងបានយកចិត្តទុកដាក់រួមសហការជាមួយយន្តការត្រួតពិនិត្យគ្រឿងញៀនទាំងអន្តរជាតិ តំបន់ អនុតំបន់ និងជាមួយប្រទេសជិតខាង ។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ យើងបានបញ្ជូនមន្ត្រីចំនួន ៤១ រូបទៅសិក្សានៅក្រៅប្រទេស។

យើងក៏បានស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាល ដើម្បីចូលរួមអនុវត្តគំរោងអនុតំបន់ចំនួន១បន្ថែមទៀត ស្តីពីការធ្វើឱ្យប្រសើរឡើងចំពោះយុវជនក្មេងៗ ដែលមានបញ្ហាដោយសារការប្រើប្រាស់បំពានគ្រឿងញៀន ATS ឱ្យទទួលបានការព្យាបាលមានប្រសិទ្ធិភាពនៅអាស៊ីបូពា (AD/RAS/06/I 13) ។

ក្រៅពីការងារខាងលើ នៅមានកិច្ចប្រជុំ២ទៀតគឺ :

១-កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និង ថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ (MOU) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។ កិច្ចប្រជុំបាន :

-ចុះហត្ថលេខាលើឯកសារគំរោងស្តីពី " ការធ្វើឱ្យប្រសើរនូវលទ្ធផលនៃការទទួលនូវការព្យាបាល ដ៏មានប្រសិទ្ធិភាពសំរាប់យុវជនដែលបានញៀនគ្រឿងញៀន ATS " ។

-អនុម័តលើសេចក្តីថ្លែងការណ៍សៀមរាប និង សេចក្តីប្រកាសពិតមាន ។ ដោយឡែកកិច្ចប្រជុំទ្វេភាគីក្នុងក្របខ័ណ្ឌថ្នាក់ប្រទេសនិងប្រទេសគឺ :

- កម្ពុជាបានឯកភាពជាមួយភាគីថៃ ថានឹងបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(BLO) ចំនួន២កន្លែងទៀតនៅក្នុងក្រុងប៉ៃលិន និង ខេត្តបាត់ដំបងរបស់កម្ពុជា ជាមួយខេត្តចន្ទបុរីរបស់ថៃ ។
- ថៃបានយល់ព្រមឱ្យកម្ពុជាទៅធ្វើទស្សនកិច្ចសិក្សា លើវិស័យអនុវត្តច្បាប់និងការព្យាបាលអ្នកញៀនគ្រឿងញៀនតាមរយៈការប្រើប្រាស់ឱសថបូរាណរួមទាំងការងារអប់រំបង្ការការប្រើបំពានគ្រឿងញៀនតាមវិស័យសាសនា ។
- វៀតណាមបានយល់ព្រមឱ្យកម្ពុជា ទៅធ្វើទស្សនកិច្ចសិក្សានិងដកបទសោធន៍លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- ចិនបានឯកភាពថានឹងរៀបចំឱ្យមានអនុស្សារណៈនៃការយោគយល់គ្នាទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយកម្ពុជា ។

២-កិច្ចប្រជុំទ្វេភាគីរវាងខេត្តស្វាយរៀង-កំពង់ចាម(កម្ពុជា) ជាមួយខេត្តតាយនីញ-ឡុងអាន(វៀតណាម) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ។ កិច្ចប្រជុំបានចុះហត្ថលេខាលើកំណត់ហេតុពីរគឺ :

-កំណត់ហេតុស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីផ្សំ(តាយនីញ-កំពង់ចាម) ។

-កំណត់ហេតុស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុគីមីផ្សំ(តាយនីញ-ឡុងអាន-ស្វាយរៀង) ។

៣-កិច្ចប្រជុំទ្វេភាគីរវាងខេត្តកោះកុង(កម្ពុជា) ជាមួយខេត្តត្រាត(ថៃ) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ។ កិច្ចប្រជុំបានចុះហត្ថលេខាលើកំណត់ហេតុស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុគីមីផ្សំ នៃខេត្តទាំងពីរ ។

## III / **អំពីផែនការជាតិ៥ឆ្នាំលើកទី១ "ស្តីពីការត្រួតពិនិត្យគ្រឿងញៀន" :**

ខ្ញុំបាទសូមអនុញ្ញាតជំរាបឯកឧត្តមប្រធាន និងអង្គប្រជុំទាំងមូលថា ផែនការនេះបានទទួលការយល់ព្រមពីរាជរដ្ឋាភិបាលសំរាប់ការអនុវត្តចាប់តាំងពីឆ្នាំ២០០៥រហូតដល់ឆ្នាំ២០១០ ។ ផែនការនេះមានទាំងអស់៦ជំពូកដែលជំពូកនិមួយៗបានចែងក្នុងគោលបំណងបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីក្លាយជាផែនការសកម្មភាពច្បាស់លាស់ដែលខ្ញុំបាទនឹងប្រគល់នាទីនេះជូនឯកឧត្តមអគ្គលេខាធិការរង **លួ រ៉ាមីន** រាយការណ៍ជូននៅពេលបន្តិចទៀត ។

## IV / **ការសន្និដ្ឋាន :**

៩ខែនេះនៅទូទាំងប្រទេសសមត្ថកិច្ចអនុវត្តច្បាប់បង្ក្រាបបាន២៦៥ករណី ។ ចំនួននេះបើប្រៀបធៀបទៅនឹងឆ្នាំ២០០៤ គឺកើនឡើង៤៨ករណី( ឆ្នាំ២០០៤មាន២១៧ករណី) ។ នេះជាការបង្ហាញឱ្យឃើញពីការប្រឹងប្រែងយ៉ាងសកម្មរបស់សមត្ថកិច្ចអនុវត្តច្បាប់ ប៉ុន្តែក៏ជាសញ្ញាបង្ហាញផងដែរថាការហូរចូលនិងការចរាចរនៃគ្រឿងញៀនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមិនទាន់កាត់បន្ថយបាននៅឡើយ ។

ចំពោះមុខសភាពការណ៍បែបនេះ ទាមទារឱ្យស្ថាប័នរដ្ឋនានាដែលមានភារកិច្ចពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនគប្បីខិតខំឱ្យបានច្រើនបន្ថែមទៀត តាមរយៈបណ្តាមធ្យោបាយដែលមានតុល្យភាពគ្នារវាងវិធានការលើកកំពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាគ្រឿងញៀន និងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពដើម្បីដោះស្រាយនិងសហការគ្នាដោះស្រាយបញ្ហាសំខាន់ៗចំពោះមុខនេះមានជាអាទិ :

-ការបង្កើនការទប់ស្កាត់នូវការហូរចូលពីតំបន់ព្រំដែនមកក្នុងប្រទេស..... គឺបញ្ហាសំខាន់បំផុត ។

-បង្កើនការបោសសំអាតការចរាចរជួញដូរចែកចាយគ្រឿងញៀនទាំងទ្រង់ទ្រាយធំនិងតូច សំខាន់គឺបង្ក្រាបឱ្យចំពួកមេក្លោងធំៗ ។ ទន្ទឹមនោះ សមត្ថកិច្ចអនុវត្តច្បាប់គប្បីស្វែងយល់អំពីភាពគ្រោះថ្នាក់ដែលពួកឈ្មួញបច្ចុប្បន្នកំពុងធ្វើចរាចរចែកចាយជាទ្រង់ទ្រាយតូចៗតាមរបៀបហ្វូងស្រមោចពាំគ្រាប់អង្ករ ដែលនេះជារូបភាពជួញដូរតូចតាចពិតមែនតែសកម្មក្នុងការចែកចាយនិងជាប់ជាប្រចាំទៀតផង ។

-សមត្ថកិច្ចអនុវត្តច្បាប់គប្បីសិក្សាពីច្បាប់ដែលទើបវិសោធនកម្ម ដើម្បីជាមូលដ្ឋានក្នុងការកសាងសំណុំរឿងចោទប្រកាន់ឱ្យបានធ្ងន់ធ្ងរតាមស្មារតីនៃច្បាប់ចំពោះឧក្រិដ្ឋជនផលិតជួញដូរគ្រឿងញៀន ។

ដោយសារមានការចរាចរចែកចាយនេះហើយ ដែលជាហេតុធ្វើឱ្យអ្នកប្រើប្រាស់កាន់តែមានចំនួនកើនឡើងជារៀងរាល់ឆ្នាំ ។ នេះជាក្តីកង្វល់របស់រាជរដ្ឋាភិបាលនិងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនក៏ដូចជាការព្រួយបារម្ភរបស់សង្គមជាតិយើងទាំងមូល ។ ការប្រើបំពានគ្រឿងញៀនកំពុងស្ថិតនៅក្នុងកំរិតមួយដែលមិនអាចសន្និភាពបាន ដោយសារការស្តែងឡើងនូវសញ្ញាជាអវិជ្ជមានពីរយ៉ាងគឺ :

ទី១-មកដល់ពេលនេះយើងនៅមិនទាន់មានរបាយការណ៍ណាមួយអាចអះអាងច្បាស់លាស់ថាអត្រានៃអ្នកប្រើបំពានគ្រឿងញៀនមានការថយចុះ ។

ទី២-ទោះបីជាចំនួនប្រជាជនភាគច្រើននៅមិនទាន់ទទួលរងគ្រោះថ្នាក់ដោយសារការប្រើបំពានគ្រឿងញៀន ក៏ប៉ុន្តែមួយផ្នែកនៃចំនួននោះបានទទួលយកនូវការអូសទាញនិងសាកល្បងរួចទៅហើយ ។

ពាក់ព័ន្ធទៅនឹងការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សូមធ្វើការកោតសរសើរដោយស្មោះចំពោះអាជ្ញាធរដែនដីនិងសមត្ថកិច្ចអនុវត្តច្បាប់របស់ខេត្ត-ក្រុងមួយចំនួនដែលកន្លងមកបានខិតខំក្នុងការប្រមូលអ្នកប្រើប្រាស់គ្រឿងញៀននៅតាមមូលដ្ឋានរបស់ខ្លួនមកធ្វើការអប់រំកែប្រែ តាមវិធីធ្វើលំហាត់ប្រាណនិងស្តារនីតិសម្បទាផ្លូវអារម្មណ៍ ។ ទោះជាកិច្ចការនេះមិនពេញលក្ខណៈគ្រប់គ្រាន់ជាការព្យាបាលក៏ដោយ ប៉ុន្តែវាបានជួយសំរាលបន្ទុករបស់រាជរដ្ឋាភិបាលមួយផ្នែក និងជៀសវាងបាននូវការបណ្តោយពួកគេឱ្យស្ថិតនៅក្រៅរង្វង់របស់សមត្ថកិច្ចគ្រប់គ្រងដែលជាហេតុងាយបង្កឱ្យកើតមាននូវបាតុភាពអសកម្មផ្សេងៗក្នុងសង្គម ក្នុងកាលៈទេសៈដែលរាជរដ្ឋាភិបាលកំពុងស្វែងរកការគាំទ្រពីដៃគូរម្ចាស់ជំនួយឬពីសហគមន៍អន្តរជាតិនានាទាំងផ្នែកហិរញ្ញវត្ថុនិងបទពិសោធន៍ ដើម្បីបង្កើតឡើងនូវមជ្ឈមណ្ឌលមួយដែលមានលទ្ធភាពគ្រប់គ្រាន់សំរាប់ការព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនទាំងអស់នោះ ។

អ្វីដែលជាការគួរឱ្យសោកស្តាយគឺដោយសារ "**<u>អ្នកញៀនគ្រឿងញៀន</u>**" ជាទូទៅត្រូវបានមជ្ឈដ្ឋាននានានៅក្នុងសង្គមតែងតែញញើតនិងមានការរើសអើង ។ ឯអ្នកញៀនខ្លួនឯងក៏ច្រើនតែគេចវេសពីការព្យាបាលតាមកន្លែងរដ្ឋឬតាមកន្លែងផ្តល់សេវាព្យាបាលផ្សេងៗ ដោយសារចង់រក្សាការសម្ងាត់និងបារម្ភខ្លាចខ្លួនត្រូវគេយកទៅផ្តន្ទាទោស ។ ការពិត ទោះជាតាមវិធីណាក៏ដោយអ្នកញៀនគ្រឿងញៀនគួរតែទទួលបាននូវការអធ្យាស្រ័យពីសហគមន៍មូលដ្ឋានដូចអ្នកជំងឺផ្សេងៗទៀតដែរ ។ ប្រសិនបើអ្នកញៀនមិនត្រូវបានទទួលការព្យាបាលទេ ពួកគេដូចជាត្រូវរុញបន្ថែមឱ្យធ្លាក់ទៅក្នុងជីវិតជាឧក្រិដ្ឋជនដូច្នោះដែរ ។

ធាតុពិតនៃបញ្ហាគឺការយល់ដឹងជាទូទៅអំពីច្បាប់និងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន របស់ប្រជាជនយើងនៅមានកំរិតនៅឡើយ ។

ខេត្តក្រុងទាំងអស់ គប្បីអនុវត្តតាមអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងសិក្ខាសាលាជាតិស្តីពីបញ្ហាគ្រឿងញៀននៅកម្ពុជា កាលពីថ្ងៃទី០៦ខែឧសភាឆ្នាំ២០០៥គឺ ***អ្នកញៀនគ្រឿងញៀនគួរតែជាជនរងគ្រោះដែលចាំបាច់ត្រូវទទួលការព្យាបាល ។ រីឯឧក្រិដ្ឋជនផលិត ជួញដូរ និង ចរាចរចែកចាយគ្រឿងញៀន ត្រូវតែដាក់ទ័ណ្ឌកម្មទៅតាមផ្លូវច្បាប់ឱ្យបានធ្ងន់ធ្ងរបំផុត ។***

## V / **ទិសដៅចំពោះមុខក្នុងការងារត្រួតពិនិត្យគ្រឿងញៀន**

១-រៀបចំគោលនយោបាយជាតិ ស្តីពីការព្យាបាលស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម ។

២-រៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាលអ្នកញៀននៅភ្នំពេញ និងនៅតាមបណ្តាខេត្តអាទិភាពមួយចំនួន ។

៣-បង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់ ។

៤-ស្រាវជ្រាវ តាក់តែងអត្ថបទអប់រំពីបញ្ហាគ្រឿងញៀនថ្មីៗ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាគ្រប់ភូមិសិក្សា ។

៥-បន្តពង្រឹងការប្រមូលទិន្នន័យអ្នកប្រើគ្រឿងញៀនឱ្យកាន់តែមានសុក្រឹត្យភាព ។

៦-បង្កើតរចនាសម្ព័ន្ធនៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនឱ្យបានដល់ថ្នាក់ស្រុក-ខ័ណ្ឌ, ឃុំ-សង្កាត់ដែលមានបញ្ហាគ្រឿងញៀនខ្លាំង ។

៧-លើកកំពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលទើបនឹងធ្វើវិសោធនកម្ម ។

៨-ពង្រឹងវិធានការទប់ស្កាត់ការចរាចរគ្រឿងញៀនទូទាំងប្រទេស ពិសេសតាមតំបន់ព្រំដែនដោយផ្តោតសំខាន់លើ ការពង្រីក និង ពង្រឹងការិយាល័យទំនាក់ទំនងព្រំដែន(BLO)បន្ថែមទៀតរវាងកម្ពុជា-វៀតណាម និង កម្ពុជា-ឡាវ ។

៩-សហការជាមួយដៃគូផ្តល់ជំនួយ ពិនិត្យលទ្ធភាពក្នុងការបង្កើតមន្ទីរពិសោធន៍គ្រឿងញៀននៅក្នុងខេត្តសំខាន់ៗ ចំនួន២ បន្ថែមទៀត ។

១០-ពង្រឹងប្រព័ន្ធអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន តាមរយៈការសំរបសំរួលឱ្យមានកិច្ចសហប្រតិបត្តការជួយគ្នាទៅវិញទៅមកខាងផ្នែកច្បាប់ រវាងស្ថាប័នអនុវត្តច្បាប់នានាទាំងក្នុងក្របខ័ណ្ឌជាតិ និង អន្តរជាតិ ។

១១-បន្តជំរុញការរៀបចំអនុក្រឹត្យនិងបទបញ្ញត្តិនានាដែលបានកំណត់ក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២-ផ្សព្វផ្សាយជំរុញ និង តាមដានការអនុវត្តន៏ផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៣-ជំរុញការកសាងផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនប្រចាំឆ្នាំ២០០៦ ដោយផ្អែកលើផែនការជាតិ៥ឆ្នាំលើកទី១(២០០៥-២០១០) ។

១៤-ជំរុញការកែសំរួលព្រះរាជក្រិត្យ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអនុក្រិត្យស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

*សូមអរព្រះគុណនិងអរគុណ !*